# វិទ្យាល័យ NOBLE PARK

## កម្មវិធី សិស្សអន្តរជាតិ

**Victoria, Australia**
ក្រសួងអប់រំ




State Government Australia



> គោលបំណងរបស់យើងគឺដើម្បីកសាងសមត្ថភាព សិស្សរបស់យើងឱ្យក្លាយទៅជាពលរដ្ឋដែលមានមហិច្ឆតា សីលធម៌ និងការទទួលខុសត្រូវដែលជាអ្នកនឹងបង្កើតការរួមចំណែកវិជ្ជមានដល់អនាគតនិងសង្គមរបស់ពួកគេ។

# សារពីនាយកវិទ្យាល័យ

**យើងសូមស្វាគមន៍យ៉ាងមោទកភាពចំពោះសិស្សអន្តរជាតិមកកាន់វិទ្យាល័យ Noble Park!**

វិទ្យាល័យរបស់យើងខិតខំដើម្បីភាពល្អប្រសើរ និងលើកកម្ពស់ក្រមសីលធម៌នៃភាពជោគជ័យសម្រាប់សិស្សទាំងអស់។ គោលបំណងរបស់យើងគឺដើម្បីកសាងសមត្ថភាពសិស្សរបស់យើងឱ្យក្លាយជាពលរដ្ឋដែលមានមហិច្ឆតា សីលធម៌ និងការទទួលខុសត្រូវ ដែលជាអ្នកនឹងចូលរួមចំណែកវិជ្ជមានដល់អនាគតរបស់ពួកគេនិងសង្គម។

តម្លៃស្នូលរបស់យើងដែលជាការគោរព ការទទួលខុសត្រូវ ភាពសុចរិត ការងារជាក្រុម និងភាពប្រសើរ ជួយបញ្ចូលតម្លៃទាំងនេះទៅក្នុងជីវិតប្រចាំថ្ងៃរបស់សិស្សយើង។

វិទ្យាល័យ Noble Park មានកម្មវិធីក្រៅកម្មវិធីសិក្សា ដែលរួមមានកម្មវិធីការងារអាជីព និងជម្រើសផ្លូវសិក្សា ការគាំទ្រពីមិត្តភក្តិ

ក្លឹបកិច្ចការសាលាធ្វើនៅផ្ទះរបស់សិស្ស កីឡាអន្តរសាលា ថ្នាក់តន្ត្រីប្រើឧបករណ៍ឯកទេស ប្រព័ន្ធចូលរួមកិច្ចការក្រុមថ្នាក់រៀន និងកម្មវិធីផ្លាស់ប្តូរវប្បធម៌ជាមួយសាលារៀនដែលជាដៃគូនៅ Shinminato នៃប្រទេសជប៉ុន។

យើងមានឯកសិទ្ធិក្នុងការមានសហគមន៍សាលាដែលមានវប្បធម៌យ៉ាងចម្រុះ ដែលបានធ្វើឲ្យអារម្មណ៍យើងចំពោះសហគមន៍មានកាន់តែស៊ីជម្រៅ កាន់តែជារបស់យើង និងកាន់តែមានការផ្តល់តម្លៃចំពោះមនុស្សមកពីគ្រប់វប្បធម៌។

'ការរាយការណ៍ជាបន្តបន្ទាប់' របស់យើងអនុញ្ញាតឱ្យឪពុកម្តាយមានរបាយការណ៍កាន់តែលម្អិតអំពីការរៀនសូត្ររបស់កូនពួកគេតាមរយៈកម្មវិធី( App) Compass ដែលមានពេញមួយឆ្នាំ (ជាជាងចុងបញ្ចប់នៃត្រីមាសនីមួយៗ)។ យើងទន្ទឹងរង់ចាំធ្វើការជាមួយឪពុកម្តាយ ចែករំលែកការអភិវឌ្ឍរបស់កូនពួកគេជាប្រចាំ។

វិទ្យាល័យរបស់យើងមានមោទកភាពក្នុងកិច្ចបំរើយ៉ាងល្អសម្រាប់សិស្សរបស់យើងដើម្បីសម្រេចបាននូវ 'លទ្ធផលសិក្សាល្អបំផុតជានិច្ច' ។ សូមកុំទើសទាល់ក្នុងការទាក់ទងមកខ្ញុំ ហើយអ្នកត្រូវបានស្វាគមន៍ជានិច្ចក្នុងការសុំការណាត់ជួបសម្រាប់ការទស្សនកិច្ចជាលក្ខណៈផ្ទាល់ខ្លួននៃវិទ្យាល័យ។

**នាយកវិទ្យាល័យ**
**Pam Dyson**



# ហេតុអ្វីត្រូវជ្រើសរើសវិទ្យាល័យ NOBLE PARK?

**ចាប់តាំងពីការបង្កើតកម្មវិធីសិស្សអន្តរជាតិរបស់យើងក្នុងឆ្នាំ 2010 មក យើងបានកំពុងស្វាគមន៍សិស្សពីប្រទេសនានារួមមាន: កម្ពុជា ចិន វៀតណាម ជប៉ុន សហរដ្ឋអាមេរិក កូរ៉េ ឥណ្ឌា ស្រីលង្កា តង់ហ្សានី ហ្ស៊ីមបាវ៉េ និងប្រទេសច្រើនទៀត។**

កម្មវិធីសិស្សអន្តរជាតិរបស់យើងគឺជាផ្នែកមួយដ៏មានតម្លៃនៃសហគមន៍ពហុវប្បធម៌របស់សាលាយើង។ យើងមានកម្មវិធី តួនាទី និងកន្លែងពិសេសជាច្រើនសម្រាប់សិស្សអន្តរជាតិ ទាំងនេះរួមមាន៖

- ស្សេវាកម្មរថយន្តក្រុងដោយឥតគិតថ្លៃ ថែមទាំងដំណើរកំសាន្តរាល់ត្រីមាស
- ការដឹកនាំរបស់និស្សិត និងក្លឹបពិភាក្សាដេញដោល
- កម្មវិធីកីឡាអន្តរសាលា និងកម្មវិធីតន្ត្រីផ្សេងៗ
- មជ្ឈមណ្ឌលភាសាអង់គ្លេសនៅនឹងកន្លែង រួមទាំងផ្ទះបាយ
- បុគ្គលិកឯកទេសខាងជំនួយពហុវប្បធម៌វៀតណាម និងកម្ពុជា ដែលជាអ្នកជួយសិស្សផ្នែកកិច្ចការសាលាដែលដាក់ឱ្យធ្វើនៅផ្ទះ និងជួយកិច្ចការបកប្រែឯកសារ។ ថែមទាំងអ្នកបកប្រែផ្ទាល់មាត់សម្រាប់ឪពុកម្តាយ និងអាណាព្យាបាលផងដែរ។

## កម្មវិធីសិក្សាដែលលើកកម្ពស់ភាពល្អប្រសើរ

យើងទទួលស្គាល់ថាសិស្សរៀនតាមរបៀបផ្សេងៗគ្នា ហើយថាក្មេងគ្រប់រូបមានចំណុចខ្លាំង និងគោលដៅនានា។ យើងមានការយល់ដឹងយ៉ាងស៊ីជម្រៅអំពីតម្រូវការសិក្សា និងរចនាប័ទ្មដែលជួយបង្កើតឱ្យមានអ្នកសិក្សាដែលមានទំនុកចិត្ត និងសហការគ្នា។

យើងផ្តល់ឱ្យសិស្ស ដែលត្រូវការជំនួយបន្ថែមលើផ្នែកអក្ខរកម្ម និងលេខ ដោយមានសម្ភារៈជំនួយសំខាន់ៗ ដើម្បីបង្កើតទំនុកចិត្ត និងបង្កើនចំណេះដឹង ហើយនិងការយល់ដឹងរបស់ពួកគេ។

វិទ្យាល័យរបស់យើងផ្តល់នូវក្លឹបបំពេញកិច្ចការសាលាគ្រូដាក់ឱ្យធ្វើនៅផ្ទះ អ្នកសម្របសម្រួលខាងអាជីព ដែលអាចជួយសិស្សជ្រើសរើសមុខវិជ្ជា និងការធ្វើផែនការសម្រាប់ផ្លូវសិក្សានៅថ្នាក់ឧត្តមសិក្សា និងគ្រូបង្រៀនដែលឧស្សាហ៍ព្យាយាម។

វិទ្យាល័យ Noble Park បានត្រូវលើកយកមកបង្ហាញនៅក្នុងសារព័ត៌មាន The HeraldSun ថាជា 'វិទ្យាល័យមួយក្នុងចំណោមវិទ្យាល័យកំពូល10 (Top Ten) នៅក្នុងរដ្ឋ Victoria ដែលត្រូវបានទទួលស្គាល់នៅក្នុងការរៀនអាន និងរៀនលេខ'។

## សកម្មភាព និងកម្មវិធីនានានាំមកនូវបទពិសោធន៍ជីវិតរបស់សិស្ស

សាលារៀនរបស់យើងផ្តល់នូវសកម្មភាពក្រៅកម្មវិធីសិក្សាជាច្រើន ដើម្បីជួយសិស្សស្វែងរកចំណាប់ចំណូលចិត្តរបស់ពួកគេ និងបង្កើតមិត្តភក្តិនៅខាងក្រៅថ្នាក់របស់ពួកគេ។







## សំឡេង និងការដឹកនាំរបស់សិស្ស

សំឡេងសិស្សពាក់ព័ន្ធនឹងសិស្សចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍ និងប្រព័ន្ធអប់រំនៃសាលារៀនរបស់ពួកគេ សិស្សចូលរួមចំណែកដល់ដំណើរការសម្រេចចិត្ត និងផ្ដល់ឥទ្ធិពលជារួមដល់លទ្ធផលដោយដាក់ចេញនូវទស្សនៈ ក្តីកង្វល់ និងគំនិតរបស់ពួកគេ។

សិស្សទទួលបានឱកាសដើម្បីចូលរួមក្នុងកម្មវិធីជាច្រើននៃសំឡេង និងការអ្នកដឹកនាំរបស់សិស្ស ដើម្បីគាំទ្រដល់ការអភិវឌ្ឍរបស់ពួកគេទៅជាយុវជនវ័យក្មេង។

## កីឡាអន្តរសាលា

សិស្សរបស់យើងចូលរួមក្នុងសកម្មភាពកីឡាជាច្រើន។ មិនថាវាជាការលេងហ្គេមពេលអាហារថ្ងៃត្រង់ជាមួយគ្រូ ការបង្វឹក ការជួយ ឬការចូលរួមក្នុងកីឡាអន្តរសាលារៀននោះទេ យើងមានអ្វីមួយសម្រាប់មនុស្សគ្រប់រូប។

គ្រូកីឡារបស់យើងទាក់ទិនកំរិតថ្នាក់រៀនជាច្រើន ហើយធ្វើការពេញទូទាំងឆ្នាំ ដើម្បីដំណើរការសកម្មភាពកីឡា ដែលអនុញ្ញាតឱ្យសាលារៀននាំមនុស្សគ្រប់រូបមកជួបជុំគ្នា។

វិទ្យាល័យរបស់យើងក៏មានគ្រឿងបរិក្ខារដូចខាងក្រោមផងដែរ ដែលគាំទ្រដល់ឱកាសនៃសកម្មភាពក្រៅកម្មវិធីសិក្សា៖

- បន្ទប់សំដែងសិល្បៈ និងបន្ទប់តន្ត្រី ថែមទាំងសាលបង្រៀន
- មជ្ឈមណ្ឌលសិក្សាថ្នាក់ខ្ពស់សម្រាប់សិស្សថ្នាក់ទី 12
- ក្លឹបពិភាក្សាដេញដោល និងក្លឹបលេងអុក
- ការសម្តែងតន្ត្រីនៅពេលប្រជុំជួបជុំសិស្សទាំងអស់ បូករួមទាំងកម្មវិធីសិល្បៈពីខាងក្រៅនៅឯ Dandenong Show។

## ការថែរក្សាសុខុមាលភាពរបស់សិស្ស

វិទ្យាល័យ Noble Park មានមោទនភាពក្នុងការបង្កើតបរិយាកាសសុខុមាលភាពវិជ្ជមាន ជាមួយនឹងតួនាទី និងសេវាកម្មដូចខាងក្រោម៖

- បុគ្គលិកសម្របសម្រួលសុខុមាលភាពសិស្សដែលដឹកនាំកម្មវិធីថែទាំសិស្ស
- គិលានុបដ្ឋាយិការបស់សាលា វេជ្ជបណ្ឌិត អ្នកឯកទេសបង្ហាត់និយាយ អ្នកឯកទេសសុខភាពផ្លូវចិត្ត និងអ្នកចិត្តសាស្ត្រដែលមកជួប
- ការទទួលនៅអាកាសយានដ្ឋាន សម្រាប់អ្នករស់នៅជាមួយគ្រួសារផ្តល់លំនៅដ្ឋានក្នុងតំបន់
- កម្មវិធីតម្រែតម្រង់ឱ្យដឹងអំពីសាលារៀន សហគមន៍ និងផ្ទះសំណាក់គ្រួសារក្នុងតំបន់
- ការជួយគាំទ្រភាសានៃបុគ្គលម្នាក់ៗ
- ការអប់រំជាបន្តបន្ទាប់ ជំនួយក្នុងការជ្រើសរើសមុខវិជ្ជា
- ទំនាក់ទំនងជាបន្តបន្ទាប់ជាមួយសិស្ស ផ្ទះសំណាក់គ្រួសារក្នុងតំបន់ និងឪពុកម្តាយ
- ការប្រឹក្សាយោបល់អំពីការងារអាជីព
- បណ្តាញគាំទ្រសិស្សអន្តរជាតិ។

## លំនៅដ្ឋានគ្រួសារក្នុងតំបន់(Homestay) សម្រាប់សិស្សអន្តរជាតិ

សិស្សអន្តរជាតិអាចស្នើសុំស្នាក់នៅតាមលំនៅដ្ឋានគ្រួសារនៅក្នុងតំបន់មូលដ្ឋាន ដែលបានរៀបចំតាមរយៈសាលារៀន។ ឬពួកគេអាចជ្រើសរើសសាច់ញាតិដែលរស់នៅក្នុងចម្ងាយសមរម្យពីវិទ្យាល័យរបស់យើង។

អ្នកផ្តល់សេវាកម្មលំនៅដ្ឋានគ្រួសារក្នុងតំបន់ភាគច្រើនរស់នៅក្នុងមូលដ្ឋាន ដោយសិស្សភាគច្រើនដើរទៅសាលារៀន ឬជិះឡានក្រុង/រថភ្លើងជិតៗ។

គ្រួសារម្ចាស់លំនៅដ្ឋានក្នុងតំបន់ផ្តល់ឱ្យសិស្សនូវ៖

- កន្លែងរស់នៅប្រកបដោយសុវត្ថិភាព សន្តិសុខ និងស្វាគមន៍
- កន្លែងរស់នៅក្នុងផ្ទះដែលអនុលោមតាមស្តង់ដារសុវត្ថិភាពកុមារ
- បន្ទប់មួយដាច់ដោយឡែកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់សិស្ស
- អាហារបីពេលក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងអាហារសម្រន់
- គ្រឿងបរិក្ខាររួមមានគ្រែ ទូខោអាវ កន្សែង និងកំរាលពូក ស្រោមពូក
- ថ្លៃចំណាយលើសេវាកម្មមានប្រយោជន៍នានារួមមាន ឧស្ម័ន អគ្គិសនី គ្រឿងកំដៅ និងទឹក ក៏ដូចជាអ៊ីនធឺណិត
- សេវាកម្មសំអាតកន្លែងរស់នៅរួម
- ការប្រើប្រាស់បន្ទប់រស់នៅក្នុងលំនៅដ្ឋាន
- សម្ភារៈសិក្សាដូចជា តុ អំពូលភ្លើងសិក្សា និងទូដាក់សៀវភៅ
- ការចូលរួមប្រជុំនៅពេលល្ងាចជាមួយឪពុកម្តាយ/គ្រូក្នុងនាមជាឪពុកម្តាយរបស់អ្នក។

មាតាបិតាម្នាក់ក្នុងចំណោមមាតាបិតាដែលផ្តល់លំនៅដ្ឋានគ្រួសារក្នុងតំបន់របស់យើងគឺ Tuyet Le មានរឿងនេះដើម្បីនិយាយអំពីកម្មវិធីរបស់យើង៖

ខ្ញុំបានផ្តល់លំនៅដ្ឋានគ្រួសារក្នុងតំបន់សម្រាប់សិស្សរស់នៅអស់រយៈពេល៥ឆ្នាំចុងក្រោយនេះ។ ចំណូលចិត្តរបស់យើងគឺការធ្វើម្ហូប និងការថែសួនច្បារ។ យើងសប្បាយចិត្តណាស់ដែលបានឃើញសិស្សរីករាយនឹងអាហារវប្បធម៌របស់យើង។ វាពិតជាល្អណាស់ដែលឃើញពួកគេធ្វើអ្វីៗរួមគ្នាជាមួយយើង ដូចជាការថែសួននៅពេលយើងមានអាកាសធាតុល្អ។ បន្ទាប់ចេញពីសាលារៀន យើងចំណាយពេលជាមួយសិស្ស ដើម្បីស្វែងយល់ពីបទពិសោធន៍របស់ពួកគេនៅឯសាលារៀន។ យើងបង្កើតទំនាក់ទំនងរឹងមាំជាមួយសិស្ស ហើយបន្តរក្សាទំនាក់ទំនងបន្ទាប់ពីចប់ថ្នាក់ទី 12»។

## ទីតាំងដែលអាចចេញចូលបានយ៉ាងងាយស្រួល

វិទ្យាល័យ Noble Park ស្ថិតនៅជាយក្រុងភាគអាគ្នេយ៍នៃទីក្រុងមែលប៊ន ហើយមានចម្ងាយប្រហែល 30 នាទីពីមណ្ឌលពាណិជ្ជកម្មកណ្តាលរបស់ក្រុងមែលប៊ន (CBD) តាមរថភ្លើង។

លក្ខណៈពិសេសខ្លះនៃតំបន់មូលដ្ឋាននេះ រួមមាន៖

- បណ្តាញដឹកជញ្ជូនសាធារណៈដែលមានសេវាកម្មល្អ
- ភូមិសង្កាត់ដែលមានវប្បធម៌ចម្រុះជាច្រើននៅក្បែរៗនោះ
- មជ្ឈមណ្ឌលលក់ទំនិញជាច្រើននៅក្នុងតំបន់មូលដ្ឋាន
- សាកលវិទ្យាល័យ Monash ស្ថិតក្នុងចម្ងាយដ៏ខ្លី។




## រឿងជោគជ័យថ្មីៗមួយ

Haireya Abudureheman ដែលជាសិស្សមកពីប្រទេសចិន បានក្លាយជាអ្នកដឹកនាំសិស្សសកម្មម្នាក់អំឡុងពេលនាងនៅ

វិទ្យាល័យ Noble Park។ នាងបានបង្ហាញពីគុណភាពនៃការដឹកនាំសិស្សដែលបំផុសគំនិតក្នុងនាមជាអនុប្រធានសិស្សប្រចាំសាលារៀននៅឆ្នាំ 2020 និងប្រធានសិស្សអន្តរជាតិនៅឆ្នាំ 2021 ដោយធ្វើការដើម្បីផ្តល់ឱ្យសិស្សទាំងអស់នូវការបញ្ចេញសំលេង។ Haireya ទទួលបានរង្វាន់ក្នុងការដឹកនាំនិស្សិតនៅក្នុងកម្មវិធីទទួលរង្វាន់ការសិក្សាសកលរបស់រដ្ឋវិចថូរៀ ឆ្នាំ 2022 (Victorian Global Learning Awards 2022)។

«ក្នុងនាមជាសិស្សអន្តរជាតិ ខ្ញុំបានតស៊ូការលំបាកនៅពេលខ្ញុំមកអូស្ត្រាលីដំបូង ដូច្នេះក្នុងនាមជាអ្នកដឹកនាំ ខ្ញុំតែងតែព្យាយាមអស់ពីសមត្ថភាពដើម្បីជួយ

សិស្សអន្តរជាតិ ជាពិសេសអ្នកដែលមកដល់ថ្មី»។

**យើងបង្កើតទំនាក់ទំនងរឹងមាំជាមួយសិស្ស ហើយបន្តរក្សាទំនាក់ទំនងបន្ទាប់ពីថ្នាក់ទី 12**



# ការទាក់ទងសាលារៀន

**វិទ្យាល័យ Noble Park**

3 Callaghan Street, Noble Park, Victoria 3174 បុគ្គលិក

សម្របសម្រួលសិស្សអន្តរជាតិ៖ Elizabeth Roshiah

ទូរស័ព្ទលេខ +61 3 9546 9066

អ៊ីមែល៖ noble.park.sc@education.vic.gov.au

វិបសាយ៖ https://www.nobleparksc.vic.edu.au/

**កម្មវិធីសិស្សអន្តរជាតិ សាលារៀនរដ្ឋក្នុងរដ្ឋវិចថូរៀ**

80 Collins Street, Melbourne Victoria 3000, Australia ទូរសព្ទលេខ៖ +61 3 7022 1000

អ៊ីមែល៖ international@education.vic.gov.au គេហទំព័រ៖ www.study.vic.gov.au

បោះពុម្ពផ្សាយដោយផ្នែកអប់រំអន្តរជាតិនៃក្រសួងអប់រំ ទីក្រុងម៉ែលប៊ន ខែមករា ឆ្នាំ 2023

© រដ្ឋវិចថូរៀ (ក្រសួងអប់រំ) ឆ្នាំ 2023

ឈ្មោះ និងលេខកូដអ្នកផ្តល់សេវាកម្ម CRICOS៖ ក្រសួងអប់រំ 00861K